

# នវានុវត្តន៍នៅក្នុងវិស័យអប់រំដែលអាចដំណើរការទៅបានដោយ បច្ចេកវិទ្យាក្នុងតំបន់អាស៊ីអាគ្នេយ៍ (TIESEA)

## របាយការណ៍វាយតម្លៃការវិភាគបញ្ហា – របាយការណ៍ប្រចាំប្រទេសកម្ពុជា

ខែមីនា ឆ្នាំ 2022

## សេចក្តីសង្ខេបខាងប្រតិបត្តិ

ផ្អែកលើសសរស្តម្ភទាំងប្រាំនៃក្របខ័ណ្ឌនៃភាពរួចរាល់ខាងផ្នែកបច្ចេកវិទ្យាក្នុងវិស័យអប់រំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB EdTech Readiness Framework) របាយការណ៍នេះពិពណ៌នាអំពីស្ថានភាពនៃវិស័យអប់រំបច្ចុប្បន្នក្នុងប្រទេសកម្ពុជាទាំងមូល ដោយមានការផ្តោតជាក់លាក់ទៅលើពីរបៀបដែលបច្ចេកវិទ្យាក្នុងវិស័យអប់រំកំពុងត្រូវបានអនុវត្តដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀន និង

ការរៀន។ សសរស្តម្ភទាំងប្រាំនៃក្របខ័ណ្ឌនេះរួមមានហេដ្ឋារចនាសម្ព័ន្ធ រដ្ឋាភិបាល សាលារៀន/គ្រូបង្រៀន មាតាបិតា/សិស្ស និងអ្នកផ្តល់បច្ចេកវិទ្យាក្នុងវិស័យអប់រំ។ តាមរយៈការកំណត់អត្តសញ្ញាណស្ថានភាពដែលមានស្រាប់នៃភាពរួចរាល់ខាងផ្នែកបច្ចេកវិទ្យា

ក្នុងវិស័យអប់រំក្នុងប្រទេសកម្ពុជាដោយប្រើក្របខ័ណ្ឌនេះ របាយការណ៍នេះព្យាយាមផ្តល់ភស្តុតាងដែលអ្នកធ្វើការសម្រេចចិត្តអាចប្រើដើម្បីកំណត់សម្គាល់ការផ្តួចផ្តើមគំនិតដែលទំនងនឹងផ្តល់នូវការរួមចំណែកជាវិជ្ជមានទៅដល់គុណភាពនៃប្រព័ន្ធអេកូសាស្ត្ររបស់

វិស័យអប់រំ និងឱកាសនានាសម្រាប់ភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន។

ប្រទេសកម្ពុជាមានប្រជាជនចំនួន 16.83 លាននាក់ក្នុងខែមករា ឆ្នាំ 2021 (51.2% នៃចំនួនប្រជាជនកម្ពុជាជាស្ត្រី) និង 8.86 លាននាក់ ដែលជាអ្នកប្រើប្រាស់អ៊ិនធឺណិតក្នុងខែមករាឆ្នាំ 2021 ដែលផ្តល់ឱ្យប្រទេសនេះនូវអត្រានៃការប្រើប្រាស់អ៊ីនធឺណិតចំនួន 52.6%[1]។ នៅឆ្នាំ 2021 ប្រទេសកម្ពុជាមានអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមចំនួន 12.00 លាននាក់ (ស្មើនឹង 71.3% នៃចំនួនប្រជាជន)។ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី 106 ក្នុងចំណោមសេដ្ឋកិច្ចនៃប្រទេសចំនួន 130 នៅក្នុងសន្ទស្សន៍ភាពរួចរាល់លើបណ្តាញអ៊ីធឺណិត (NRI) 2021 ដោយមានផលប៉ះពាល់ (ដល់ជីវិតរស់នៅ) ជាចំណុចខ្លាំង និងអភិបាលកិច្ចជាចំណុចខ្សោយចម្បង (ទំនុកចិត្ត)។

បរិមាណនៃគម្លាតយេនឌ័រនៅក្នុងបច្ចេកវិទ្យាក្នុងវិស័យអប់រំត្រូវបានរួមបញ្ចូលនៅក្នុងឧបសម្ព័ន្ធទី 3 នៃរបាយការណ៍នេះ។ សរុបរួមមក ការរកឃើញរបស់របាយការណ៍នេះគឺថា រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាមានការប្តេជ្ញាចិត្តចំពោះសមភាពយេនឌ័រ ហើយកាលពីអំឡុងពេលប្រាំឆ្នាំកន្លងមកនេះ សមាមាត្រនៃស្ត្រីដែលចូលរួមនៅក្នុងកម្លាំងការងារបានកើនឡើងចំនួន 5% ទៅ 84% ប៉ុន្តែឱកាសរបស់ស្ត្រីនៅក្នុងផ្នែកបច្ចេកវិទ្យាក្នុងវិស័យអប់រំនៅមានកម្រិតជាខ្លាំងដោយសារជំនឿក្នុងគ្រួសារនិងវប្បធម៌ និងគុណតម្លៃដែលមើលឃើញផ្នែកបច្ចេកវិទ្យាក្នុងវិស័យអប់រំថាជាវិស័យដែលគ្រប់គ្រងដោយបុរស។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងសាលាមធ្យមសិក្សាទុតិយភូមិ សមាមាត្រនៃក្មេងស្រីដែលនៅសេសសល់ក្នុងការអប់រំមានខ្ពស់ជាង (54%) ក្មេងប្រុស (46%) ហើយក្មេងស្រីកំពុងជ្រើសរើសមុខវិជ្ជា STEM កាន់តែច្រើនឡើង ទោះបីជាពួកគេទំនងជាបន្តទៅជំនាញវិទ្យាសាស្ត្រជាជាងជម្រើសបច្ចេកវិទ្យានៅសាកលវិទ្យាល័យក៏ដោយ។ ស្ត្រីកាន់តែច្រើនឥឡូវនេះបានក្លាយទៅជាអ្នកដែលប្រកបការងារឱ្យខ្លួនឯង (65% នៃសហគ្រាសធុនតូចនិងមធ្យមទាំងអស់ឥឡូវនេះដំណើរការដោយ និងជាកម្មសិទ្ធិរបស់ស្ត្រី)

[1] Kemp, 2021

ហើយជំនាញរបស់ពួកគេនៅក្នុងការប្រើប្រាស់ឱកាសធ្វើអាជីវកម្មអេឡិចត្រូនិកនៅលើអ៊ីនធឺណិតគឺជាកត្តាជោគជ័យដ៏សំខាន់មួយនៅទីនេះ។ ជារួម គ្រូបង្រៀនជាស្ត្រីមានជំនាញផ្នែកបច្ចេកវិទ្យាក្នុង វិស័យអប់រំ និងកម្រិតអក្ខរកម្មឌីជីថលទាបជាងបុរស។ បើទោះបីជានៅក្នុងប្រទេសទាំងមូលជាទូទៅ អ្នកមានទូរសព្ទស្មាតហ្វូនមានកម្រិតខ្ពស់ក៏ដោយ ស្ត្រីនៅជនបទគឺជាក្រុមប្រជាជនដែលមិនទំនងនឹងមានទូរសព្ទដៃបំផុត។

## ហេដ្ឋារចនាសម្ព័ន្ធ

វិសាលភាពនៃការតភ្ជាប់បណ្តាញនៅនឹងកន្លែងនៅមានកម្រិតទាបខ្លាំងក្នុងប្រទេសកម្ពុជា ហើយប្រទេសនេះបានផ្លាស់ប្តូរយ៉ាងឆាប់រហ័សចេញពីហេដ្ឋារចនាសម្ព័ន្ធដែលមានថ្លៃចំណាយដើមខ្ពស់នេះ ហើយក្នុងការផ្តោះទៅរកការប្រាស្រ័យទាក់ទងតាមបណ្តាញ ចល័ត ជាមួយនឹងការតភ្ជាប់បណ្តាញទូរសព្ទចល័តចំនួន 21.18 លានខ្សែ ប្រទេសកម្ពុជាក៏ផ្តល់ជូននូវសេវាកម្មទូរសព្ទដៃដែលមានតម្លៃសមរម្យបំផុតនៅក្នុងទ្វីបអាស៊ី ដោយមានថ្លៃជាវសេវាកម្មប្រចាំខែជាមធ្យមចំនួនប្រហែល $4 ។ មានក្រុមហ៊ុនផ្តល់សេវាទូរសព្ទចល័តចំនួនប្រាំមួយនៅក្នុងប្រទេសកម្ពុជា ហើយប្រទេសនេះជាប់ចំណាត់ថ្នាក់ទី 66 នៅក្នុងពិភពលោកចំពោះតម្លៃទិន្នន័យទូរសព្ទចល័ត ដោយជាមធ្យមមានតម្លៃ $1.50 សម្រាប់ទិន្នន័យ 1 GB (Cable.co.uk, 2020)។ មានតែ 13.3% នៃគ្រួសារកម្ពុជាប៉ុណ្ណោះ ដែលមានលទ្ធភាពប្រើប្រាស់កុំព្យូទ័រ ទោះបីជាមានគ្រួសារចំនួន 41.1% នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (ITU, 2019) មានលទ្ធភាពប្រើប្រាស់កុំព្យូទ័រក៏ដោយ។ ឧបករណ៍ចល័ត (ទូរសព្ទស្មាតហ្វូន) ត្រូវបានប្រើច្រើនបំផុតដើម្បីចូលប្រើអ៊ីនធឺណិត ដោយមានអត្រានៃការប្រើប្រាស់ចំនួន 125.8% ក្នុងចំណោមប្រជាជនទូទៅ។ 97.6% នៃគ្រួសារកម្ពុជាមានអគ្គិសនីប្រើប្រាស់។

ទម្រង់ប្រព័ន្ធផ្សព្វផ្សាយដែលមានប្រជាប្រិយភាពបំផុតនៅក្នុងប្រទេសកម្ពុជាគឺទូរទស្សន៍ ដែលអាចទៅដល់ 96% នៃប្រជាជននៅក្នុងប្រទេសតាមរយៈប៉ុស្តិ៍ទូរទស្សន៍ចំនួន 18 របស់ខ្លួន។ ក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ 19 កម្មវិធីទូរទស្សន៍អប់រំបានចាក់ផ្សាយតាមទូរទស្សន៍ជាតិកម្ពុជា និងបណ្តាញទូរទស្សន៍ខ្សែកាបផ្សេងទៀតទូទាំងប្រទេស ដូចជា TVK2 ដែលទើបបង្កើតថ្មីសម្រាប់ការផ្សាយកម្មវិធីអប់រំ ទូរទស្សន៍តេជោ DTV ប៉ុស្តិ៍លេខ 22 និងបណ្តាញទូរទស្សន៍ខ្សែកាបថ្មីចំនួន 55 ប៉ុស្តិ៍[2]។

## រដ្ឋាភិបាល

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី 4, ផែនការមេ ICT ឆ្នាំ 2020, គោលនយោបាយអភិវឌ្ឍន៍ទូរគមនាគមន៍ ICT (T-ICT) ឆ្នាំ 2020, ច្បាប់ស្តីពីទូរគមនាគមន៍ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ ICT គឺជាគោលនយោបាយទាំងអស់ដែលបង្កើតដោយរាជរដ្ឋាភិបាលកម្ពុជា (RGC) ។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ 124 នៅក្នុងសន្ទស្សន៍នៃការអភិវឌ្ឍរដ្ឋាភិបាលអេឡិចត្រូនិក របស់អង្គការសហប្រជាជាតិ និងចំណាត់ថ្នាក់លេខ 129 ក្នុងសន្ទស្សន៍នៃការចូលរួមតាមប្រព័ន្ធអេឡិចត្រូនិក[3] ដែលជាការបញ្ជាក់ឱ្យឃើញថា អត្ថបទគោលនយោបាយទាំងនេះត្រូវតែបំប្លែងទៅជាការអនុវត្ត និងយុទ្ធសាស្ត្រជាក់ស្តែង។

នៅក្នុងឆ្នាំ 2016 ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តក្របខ័ណ្ឌកម្មវិធីសិក្សាមួយ ហើយក្នុងឆ្នាំ 2018 គ្រប់កម្រិតនៃសាលារៀនទាំងអស់បានដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាមួយដែលបានរួមបញ្ចូលគោលគំនិតនិងបច្ចេកទេស ដែលផ្តោតទៅលើសិស្ស តាមរយៈការសិក្សាដោយផ្អែកទៅលើការចោទសួរ។ ឥឡូវនេះ កម្មវិធីកុំព្យូទ័រគឺជាផ្នែកមួយនៃកម្មវិធីសិក្សាជាតិថ្មីសម្រាប់សិស្សថ្នាក់ទី 4 ដល់ទី 12 ។ លើសពីនេះ មានកម្មវិធីដែលផ្តល់ជូនខ្លឹមសារអំពីមុខវិជ្ជា ICT ដូចជាគម្រោងសាលារៀនជំនាន់ថ្មី ដែលផ្តោតទៅលើមុខវិជ្ជា STEM, ICT និងជំនាញគិតវិភាគ និងអង្គការ Caring for Cambodia ដែលបង្កើនការត្រៀមខ្លួនរបស់កម្លាំងការងារ និងជំនាញក្នុងការអប់រំដូច្នេះហើយសិស្សអាចធ្វើការនៅក្នុងវិស័យដែលមានការរីកចម្រើន រួមទាំង ICT ហើយកម្មវិធីទាំងពីរនេះសហការជាមួយនឹងក្រសួងអប់រំ យុវជននិងកីឡា។

ផែនការអភិវឌ្ឍន៍វិស័យអប់រំមានបំណងបង្កើតប្រព័ន្ធមួយនៅឆ្នាំ 2030 ដែលបង្កើនជាអតិបរមានូវការប្រើប្រាស់នូវឱកាស ICT និងការតភ្ជាប់ទិន្នន័យសម្រាប់ការផ្លាស់ប្តូរព័ត៌មាន ការវិភាគ របាយការណ៍ និងមតិកែលម្អក្នុងពេលវេលាជាក់ស្តែងសម្រាប់ការវាស់វែងការអនុវត្តការអប់រំ។ ភាគីដែលពាក់ព័ន្ធ (អ្នកគ្រប់គ្រងនិងរដ្ឋបាលសាលា ឪពុកម្តាយនិងសហគមន៍ក្នុងតំបន់ ក្រសួងនិងនាយកដ្ឋានអប់រំយុវជននិងកីឡាថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MoEF) វិទ្យាស្ថានជាតិស្ថិតិ (NIS) និងដៃគូ (ODA) ប្រព័ន្ធ EMIS (ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំ) នឹងគ្រប់គ្រង រៀបចំផែនការ និងតាមដាន។ នៅក្រោម EEQP2 នេះមានន័យថានិងមានការផ្លាស់ប្តូរពីប្រព័ន្ធអតិថិបករណ៍និងសេវូបករណ៍ (client-server system) ទៅកាន់ប្រព័ន្ធរួមបញ្ចូលនឹងដែលដំណើរការនៅលើគេហទំព័រ ក៏ដូចជាវិមជ្ឈការ និងការផ្តោតជាថ្មីលើប្រព័ន្ធតាមដានសិស្ស និងប្រព័ន្ធព័ត៌មានសាលារៀន (SIS) ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពី CDPF (មូលនិធិភាពជាដៃគូក្នុងការអភិវឌ្ឍសមត្ថភាព) ដែលត្រូវបានគ្រប់គ្រង និងផ្តល់ហិរញ្ញប្បទានក្រោមការណែនាំរបស់អង្គការ UNICEF ក្នុងភាពជាដៃគូជាមួយក្រសួងអប់រំ យុវជននិងកីឡា សហភាពអឺរ៉ុប និងអង្គការ SIDA។

---

[2] Aide et Action Southeast Asia, 2020

[3] UN, 2020

# សាលារៀន / គ្រូបង្រៀន

ដើម្បីអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន និងធ្វើកំណែទម្រង់វិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀននៅ NIE, TEC និង RTTC ដើម្បីធានាឱ្យបាននូវភាពពាក់ព័ន្ធនៃលទ្ធផលពីការបណ្តុះបណ្តាលជាពិសេសក្នុងមុខជំនាញ STEM និង ICT ការបណ្តុះបណ្តាលក្នុងពេលបំរើការការងារ និងការបណ្តុះបណ្តាលមុនចូលបម្រើការងារ ត្រូវតែរួមបញ្ចូលវិធីសាស្ត្របង្រៀនបែបទំនើបនិងថ្មី និងរួមបញ្ចូលជំនាញ ICT ។
ដើម្បីអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន និងធ្វើកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀននៅ NIE, TEC, ហើយ RTTC ត្រូវតែរួមបញ្ចូលវិធីសាស្ត្របង្រៀនតាមបែបទំនើបនិងថ្មី និងរួមបញ្ចូលជំនាញ ICT ។និងដើម្បីអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន និងធ្វើកំណែទម្រង់ក្នុងការអនុវត្ត ប៉ុន្តែ ការបណ្តុះបណ្តាលជំនាញ ICT សម្រាប់គ្រូបង្រៀនមុនពេលចូលបម្រើការមានកម្រិតកំណត់ត្រឹមជំនាញ
កុំព្យូទ័រជាមូលដ្ឋានដូចជា Microsoft Office Suite, កម្មវិធីរុករកលើអ៊ីនធឺណិត និងការប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ Windows នៅលើកុំព្យូទ័រផ្ទាល់ខ្លួន និងគ្រូបង្រៀនដែលកំពុងបម្រើការ ដែលមិនទទួលបានការបណ្តុះបណ្តាលអំពីជំនាញ ICT លើកលែងតែគ្រូមកពីគម្រោងសាលារៀនជំនាន់ថ្មី។

វិទ្យាស្ថានអប់រំជាតិ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀននៅក្នុងតំបន់ចំនួនបួន ដែលបម្រើការជាវិទ្យាស្ថានមជ្ឈការសម្រាប់ការបណ្តុះបណ្តាលរបស់រដ្ឋាភិបាលក្នុងពេលបម្រើការងារនិងមុនពេលបម្រើការងារផ្តល់ជូនក្របខណ្ឌបណ្តុះបណ្តាលដោយផ្អែកទៅលើពេលវេលាជាជាងក្របខ័ណ្ឌជាផ្អែកដែលផ្អែកទៅលើលទ្ធផល
ប៉ុន្តែការបណ្តុះបណ្តាលជំនាញ ICT មុនពេលចូលបម្រើការងារដំបូងត្រូវបានផ្តល់ជូន ហើយការបណ្តុះបណ្តាលក្នុងពេលបម្រើការងារមានកំណត់ត្រូវបានផ្តល់ជូន ឬមិនមានតែម្តង។
យោងតាមការស្ទង់មតិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី[4] បានឱ្យដឹងថាប្រហែល 5% នៃគ្រូបង្រៀនបង្កើតស្លាយក្នុងកម្មវិធី PowerPoint សម្រាប់គោលបំណងនៃការបង្រៀនពីប្រចាំសប្តាហ៍ទៅប្រចាំថ្ងៃ ខណៈពេលដែល 12% បង្កើតវីដេអូពីប្រចាំសប្តាហ៍ទៅប្រចាំថ្ងៃ។ ទោះជាយ៉ាងណាក៏ដោយ គ្រូបង្រៀនជាង 70% បានបង្ហាញថាពួកគេ 'កម្រ' ទៅ 'មិនដែល' បង្កើតការវាយតម្លៃ/កម្រងសំណួរតាមអ៊ីនធឺណិតសម្រាប់សិស្ស។ ច្រើនជាង 76% នៃគ្រូបង្រៀនដែលត្រូវបានគេស្ទង់មតិបាននិយាយថា ពួកគេមិនប្រើប្រាស់អ៊ីមែល ឬកម្មវិធីចែករំលែកឯកសារដូចជា Google Drive, OneDrive ឬ Dropbox ជាប្រចាំនោះទេ។
មិនមែនគ្រូទាំងអស់សុទ្ធតែហាក់ដូចជាមានលទ្ធភាពចូលប្រើកុំព្យូទ័រជាញឹកញាប់ដើម្បីប្រើប្រាស់ប្រព័ន្ធចែករំលែកឯកសារឱ្យបានត្រឹមត្រូវនោះទេ។ ដើម្បីធ្វើទំនាក់ទំនងឯកសាររវាងពួកគេឬជាមួយនឹងកូនសិស្ស មនុស្សភាគច្រើនប្រើប្រាស់ឧបករណ៍ផ្ញើសារសង្គមដូចជា Telegram ឬនៅលើវេទិកាផ្សព្វផ្សាយសង្គមដូចជា Facebook ។ នេះបញ្ជាក់ឱ្យឃើញកង្វះខាតនៃការយល់ដឹងដោយសាស្ត្រាចារ្យទៅលើអំណាចនៃការសហការគ្នា (គុណតម្លៃ) នៃប្រព័ន្ធចែករំលែកឯកសារ ឬក៏ខ្វះខាតឧបករណ៍សមស្របដើម្បីប្រើប្រាស់ពួកគេ។

កង្វះកុំព្យូទ័រ លទ្ធភាពចូលប្រើប្រាស់អ៊ិនធឺណិតមិនគ្រប់គ្រាន់ឬមិនមានតែម្តង ជាពិសេសល្បឿនអ៊ីនធឺណិតដែលមិនគ្រប់គ្រាន់និង/ឬមិនមានស្ថេរភាពគឺជាឧបសគ្គដ៏ចម្បងទាំងអស់ក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យអប់រំនៅក្នុងសាលារៀន។
ក៏មានភាពកម្រនៃបុគ្គលិកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធផ្នែកបច្ចេកវិទ្យាក្នុងវិស័យអប់រំ និងផ្តល់ជូនជំនួយគាំទ្រដល់អ្នកប្រើប្រាស់នៅក្នុងសាលា។ មានតែ 17% នៃវិទ្យាល័យ និង 5% នៃអនុវិទ្យាល័យប៉ុណ្ណោះមានបន្ទប់កុំព្យូទ័រ នេះបើយោងតាមក្រសួងអប់រំ យុវជននិងកីឡា (2019) ។ 40% នៃសាលាវិទ្យាល័យមានការតភ្ជាប់អ៊ីនធឺណិត ប៉ុន្តែក្នុងករណីភាគច្រើនអ៊ីនធឺណិតនេះគឺត្រូវបានប្រើសម្រាប់តែគោលបំណងរដ្ឋបាលនៅក្នុងការិយាល័យរដ្ឋបាលរបស់សាលាប៉ុណ្ណោះ។
ប្រទេសកម្ពុជាបានដាក់ចេញនូវកិច្ចខិតខំប្រឹងប្រែង
និងថវិកាជាច្រើនដើម្បីអភិវឌ្ឍនិងអនុវត្តយុទ្ធសាស្ត្រក្នុងការកែលម្អការប្រើប្រាស់ជំនាញ ICT នៅក្នុងវិស័យអប់រំ។ ម៉្យាងវិញទៀត
សាលារៀនប្រើប្រាស់ទម្រង់ពាក្យជាក្រដាសជាច្រើនដើម្បីប្រមូលទិន្នន័យដោយដៃសម្រាប់ការតាមដាននិងគោលបំណងវាយតម្លៃ ដូចជាព័ត៌មានអំពីការចុះឈ្មោះរបស់សិស្ស ថ្នាក់រៀន និងកំណត់ត្រាវត្តមាន សម្រាប់ប្រព័ន្ធ EMIS ម្តងក្នុងមួយឆ្នាំ ហើយបន្ទាប់មកបញ្ចូលទិន្នន័យនោះទៅក្នុងកុំព្យូទ័រនៅឯការិយាល័យរដ្ឋបាលរបស់សាលា។

ជាង 95% នៃអ្នកឆ្លើយតបទៅនឹងការស្ទង់មតិរបស់គ្រូ[5] យល់ស្របថាសមត្ថភាពក្នុងការចែករំលែកគំនិតបទពិសោធន៍បង្រៀន និងការណែនាំគឺ 'មានសារៈសំខាន់' ឬ 'មានសារៈសំខាន់ខ្លាំង' សម្រាប់សហគមន៍នៃការអនុវត្ត។
ភាគច្រើនបំផុតនៃគ្រូបង្រៀននៅតែប្រើប្រាស់ការអនុវត្តនៃការសរសេរសំបុត្រតាមបែបចាស់
ឬការអំពាវនាវទៅកាន់មាតាបិតាតាមរយៈសិស្សឬមិត្តភក្តិរបស់សិស្ស (អំពីបញ្ហាក្នុងការសិក្សា ការអវត្តមាន និងបញ្ហាអាកប្បកិរិយានានា)។ សាលារៀនអាចប្រើប្រាស់ប្រព័ន្ធផ្ញើសារសង្គមដែលមានស្រាប់ដែលគ្រូបង្រៀននិងឪពុកម្តាយមានភាពថ្នឹកជាមួយ ដូចជាក្រុម Telegram ឬក្រុម Facebook ដើម្បីបង្កើតជាក្រុមរបស់ឪពុកម្តាយសម្រាប់ថ្នាក់នីមួយៗ
និងសាលាទាំងមូលជាប្រព័ន្ធប្រាស្រ័យទាក់ទងសម្រាប់គ្រូបង្រៀននិងសាលាដើម្បីទាក់ទងទៅកាន់មាតាបិតាទាំងអស់។

ក្មេងជំទង់ និងមនុស្សពេញវ័យចន្លោះពី 20% ទៅ 37% បានចម្លង ឬផ្លាស់ប្តូរទីតាំងឯកសារ ឬថតឯកសារ ប្រើប្រាស់ឧបករណ៍ចម្លង និងបិទភ្ជាប់ដើម្បីចម្លងនៅក្នុងឯកសារ ផ្ញើអ៊ីមែលជាមួយឯកសារភ្ជាប់ និងផ្ទេរព័ត៌មានរវាងកុំព្យូទ័រ និងឧបករណ៍ផ្សេងទៀត។ ទោះជាយ៉ាងនេះក្តី ត្រឹមតែ2.5% បានតភ្ជាប់

[4] ធនាគារអភិវឌ្ឍន៍អាស៊ី ថ្ងៃទី 25 ខែមករាឆ្នាំ 2021 ការវិភាគស្ថានភាពរបស់ប្រទេសអំពីបច្ចេកវិទ្យាក្នុងវិស័យអប់រំនៃប្រទេសកម្ពុជា។
[5] ធនាគារអភិវឌ្ឍន៍អាស៊ី ថ្ងៃទី 25 ខែមករាឆ្នាំ 2021 ការវិភាគស្ថានភាពរបស់ប្រទេសអំពីបច្ចេកវិទ្យាក្នុងវិស័យអប់រំនៃប្រទេសកម្ពុជា។

និងរៀបចំការកំណត់ឧបករណ៍ថ្មី បានបង្កើតបទបង្ហាញតាមប្រព័ន្ធអេឡិចត្រូនិក ដោយប្រើសុសវែរធ្វើបទបង្ហាញបានសម្គាល់ ទាញយក ដំឡើង និងរៀបចំការកំណត់របស់សុសវែរ ឬបានសរសេរកម្មវិធីនៅក្នុងកុំព្យូទ័រ។

## សិស្ស/មាតាបិតា

ក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ 19 ការទាមទារឱ្យមានការសិក្សាពីចម្ងាយបានបង្កឱ្យមានឧបសគ្គកាន់តែច្រើនឡើងចំពោះប្រព័ន្ធ ICT របស់កម្ពុជា។ លទ្ធភាពរបស់សិស្សក្នុងការចូលប្រើប្រាស់ធនធានអប់រំតាមអ៊ីនធឺណិត និងការសិក្សាពីចម្ងាយតាមរយៈការរួមផ្សំគ្នានៃទូរសព្ទចល័ត កុំព្យូទ័រ ទូរទស្សន៍ និងវិទ្យុត្រូវបានគេរកឃើញថាមានបញ្ហាជាខ្លាំង។ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំធានាឱ្យមានដំណើរការល្អនៃការណែនាំពីចម្ងាយ ដោយផ្តល់ជូននូវជម្រើសសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងៗ ដោយសហការជាមួយដៃគូអភិវឌ្ឍ ដូចជាអង្គការ UNICEF និង UNESCO ។ គោលបំណងគឺដើម្បីផ្តល់ជូនការចូលរួមយ៉ាងសកម្មដោយការប្រើប្រាស់ការរួមផ្សំគ្នានៃមេរៀន និងលំហាត់ដែលផ្តល់ជូនដោយគ្រូពីក្នុងថ្នាក់បង្រៀន បូករួមផ្សំជាមួយនឹងខ្លឹមសារតាមអ៊ីនធឺណិតដែលផ្តល់ជូនដោយក្រសួង តាមរយៈវេទិកាជាច្រើនដូចជាទំព័រ Facebook និងកម្មវិធី Youth ព្រមទាំងវេទិកាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកដូចជាកម្មវិធីក្នុងទូរសព្ទឈ្មោះ E-School Cambodia។ ប៉ុន្តែសមត្ថភាពក្នុងការចូលប្រើប្រាស់សម្ភារៈតាមអ៊ីនធឺណិតទាំងនេះមិនមានលក្ខណៈជាសកលនោះទេ។

ខណៈពេលដែលសិស្សនៅក្នុងទីក្រុងធំៗដូចជា ភ្នំពេញ និងសៀមរាប មានលទ្ធភាពទទួលបាន Wi-Fi នៅក្នុងហាងកាហ្វេនិងថ្នាក់រៀនក៏ដោយ ភូមិភាគច្រើននៅក្នុងទីតាំងដាច់ស្រយាលនិងមិនសូវមានមនុស្សរស់នៅមានភាពខ្វះខាតហេដ្ឋារចនាសម្ព័ន្ធខាងប្រព័ន្ធឌីជីថល ដែលចាំបាច់ដើម្បីគាំទ្រដល់ការសិក្សា (តាមអ៊ីនធឺណិត)។ នៅលើ Telegram និង Facebook មានក្រុម និងបណ្តាញរាប់រយដែល ផ្តោតទៅលើមុខវិជ្ជារបស់សាលា ដូចជា គណិតវិទ្យា ភាសាអង់គ្លេស រូបវិទ្យា និងគីមីវិទ្យា ក៏ដូចជាសកម្មភាពដូចជាកម្មវិធីសិក្សា ខ្លឹមសារសិក្សា និងការប្រឡង ដែលគ្រូ និងសាលាអាចចែករំលែកធនធាន។ ទីតាំងជនបទមានធនធានតិចទាក់ទងនឹងជំនាញបច្ចេកទេស និងតម្លៃសមរម្យ ខណៈដែលតំបន់ទីក្រុងមានធនធានច្រើនទៀត - ការចូលប្រើឧបករណ៍ សេវាកម្មឧបករណ៍។

## អ្នកផ្តល់សេវា - ក្រុមហ៊ុន និងភាពជាដៃគូសាធារណៈ និងឯកជន

អង្គការ UNESCO និងក្រសួងអប់រំ បានបង្កើតវគ្គបណ្តុះបណ្តាលសម្រាប់ការអប់រំកម្រិតមធ្យមសិក្សា/មូលដ្ឋានក្នុងឆ្នាំ 2019 និងស្ថិតក្នុងចំណោមដៃគូ និងអ្នកគាំទ្ររបស់ផ្នែកបច្ចេកវិទ្យាក្នុងវស័យអប់រំ។ សហភាពសហព័ន្ធយុវជនកម្ពុជា បានសហការជាមួយ E-school Cambodia ដើម្បីបង្កើតវេបផតថល ដែលផ្តល់មាតិកាឥតគិតថ្លៃដល់សិស្សនៅថ្នាក់ទី 1 ដល់ទី 12។ អង្គការ JICA បានបង្កើតថ្នាក់តាមអ៊ីនធឺណិត ដោយសហការជាមួយក្រសួងអប់រំ ដែលនឹងមាននៅលើកម្មវិធីមួយឈ្មោះថា “Think!”។ SALA, Koompi, Tablet on Wheels (ToW), KAPE, EDEMY, E-School Cambodia, STEM Cambodia, E2STEM, Go Digital ASEAN Initiative, InSTEDDiLab, ArrowDot, SystemExperts, និង IT STEP Academy គឺជាអ្នកផ្តល់សេវាផ្នែកបច្ចេកវិទ្យាក្នុងវិស័យអប់រំក្នុងប្រទេសកម្ពុជាផ្សេងទៀត និងត្រូវបានពិពណ៌នាពេញលេញនៅក្នុងឧបសម្ព័ន្ធលេខ 2 នៃរបាយការណ៍នេះ។

ទិសដៅគោលនយោបាយ IR4.0 គឺដើម្បីបញ្ចូលក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថល និងសង្គមត្រឹមឆ្នាំ 2035 ដែលផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិតល្បឿនលឿនដើម្បីគាំទ្រដល់ជីវភាពរស់នៅវៃឆ្លាតនៃប្រជាជន 95% នៃប្រទេស, បទបញ្ញត្តិលើហេដ្ឋារចនាសម្ព័ន្ធបន្ថែម, ការចែករំលែកហេដ្ឋារចនាសម្ព័ន្ធ, មជ្ឈមណ្ឌលនិងបណ្តាញសមូហកម្មរបស់ទិន្នន័យរដ្ឋាភិបាល និងការលើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន ដើម្បីដោះស្រាយចន្លោះប្រហោងនៃហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្នក៏ដូចជាជំនួយដល់បច្ចេកទេសនោះផងដែរ។ តួនាទីនៃបច្ចេកវិទ្យាក្នុងវិស័យអប់រំនៅក្នុងការអប់រំជាសាធារណៈត្រូវបានលើកយកមកបង្ហាញពេលដែលរដ្ឋាភិបាលបានប្រកាសអំពីការសិក្សាពីចម្ងាយក្នុងអំឡុង ជំងឺរាតត្បាតកូវីដ 19 ជាសកល។

សេចក្តីសង្ខេបអំពីប្រតិបត្តិការនេះបង្ហាញពីលទ្ធផលរកឃើញជាបឋម
ហើយការបោះពុម្ពផ្សាយជាផ្លូវការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនឹងត្រូវធ្វើឡើង
តាមពេលកំណត់

ADB
JFPR Japan Fund for Prosperous and Resilient Asia and the Pacific
From the People of Japan
ibf INTERNATIONAL CONSULTING
Learning Possibilities